Hong Leong Bank

# បញ្ញត្តិ និងលក្ខខណ្ឌទូទៅសម្រាប់គណនី

## ផ្នែកទី ១: បញ្ញត្តិទូទៅ

### ១. និយមន័យ

នៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះពាក្យ និងឃ្លាដូចខាងក្រោមនេះមានន័យដូចដែលបានកំណត់ចំពោះពាក្យ និង ឃ្លានោះ លើកលែងតែបរិបទតម្រូវជាក់លាក់ផ្សេងពីនេះ។

"គណនី" សំដៅលើគណនីមួយ ឬ ច្រើនរបស់អតិថិជន ដែលបានបើកនិងមានជាមួយ ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី ("HLBCAM") និងត្រូវរាប់បញ្ចូលទាំងគណនីថ្មីណាមួយផ្សេងទៀតដែលអតិថិជនអាចនឹងបើក ជាមួយHLBCAM នៅពេលណាមួយនាអនាគត។

"គណនីចរន្តអាជីវកម្មមានការប្រាក់" សំដៅលើគណនីដូចដែលបានកំណត់នៅក្នុងផ្នែក២ប្រការ២ នៃបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

"គណនីចរន្តអាជីវកម្ម" សំដៅលើគណនីដូចដែលបានកំណត់នៅក្នុងផ្នែក២ប្រការ៤នៃបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

"វិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់" សំដៅលើឯកសារកត់ត្រាដែល HLBCAM បានផ្តល់អោយអតិថិជនជាភស្តុតាងបញ្ជាក់អំពីចំនួនទឹកប្រាក់របស់អតិថិជនដែលបានដាក់នៅក្នុងគណនីប្រាក់បញ្ញើមានកាលកំណត់ជាមួយ HLBCAM ។

"អតិថិជន" សំដៅលើនីតិបុគ្គល ឬ រូបវ័ន្តបុគ្គលដែលអាចទិញផលិតផល ឬ សេវាកម្មពី HLBCAM និងមានរួមបញ្ចូលទាំងឯកត្តជន សហកម្មសិទ្ធិ សហគ្រិន ក្រុមហ៊ុន សមាគម សហព័ន្ធ អង្គការ នីតិបុគ្គលនានាដែលត្រូវបានបង្កើតឡើងដោយច្បាប់ និងតាមករណីដែលអាចអនុវត្តបាន រួមទាំងតំណាងផ្ទាល់ខ្លួន ឬអ្នកស្នង លើកលែងតែមានចែងផ្សេងពីនេះក្នុងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ ឬ ដោយ HLBCAM នៅពេលណាមួយនាអនាគត ។

"គណនីប្រាក់បញ្ញើមានកាលកំណត់" សំដៅលើគណនីដូចដែលបានកំណត់នៅក្នុងផ្នែក២ប្រការ៥ នៃបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

"HLBCAM" សំដៅលើ ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី រួមបញ្ចូលទាំងសាខារបស់ខ្លួន និងអ្នកស្នង និងអ្នកទទួលសិទ្ធិនោះ។

"គណនីរួមគ្នា" សំដៅលើគណនីដូចដែលបានកំណត់នៅក្នុងផ្នែក២ប្រការ២ នៃបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

"NBC" សំដៅលើធនាគារជាតិនៃកម្ពុជា។

"របាយការណ៍គណនីអេឡិចត្រូនិច" សំដៅលើកំណត់ត្រាដែលបានផ្តល់ជូនអតិថិជន ដែលសង្ខេបរាល់ប្រតិបត្តិការនៅក្នុងគណនីចរន្តក្នុងកំឡុងពីរយៈពេលមួយពីកំណត់ត្រាចាស់រហូតដល់រយៈពេលមួយទៀតដែលមានកំណត់ត្រាចុងក្រោយបង្អស់ ដែលអាចផ្តល់ដល់អតិថិជនតាមរយៈ http://www.hlb.com.my/kh។

"កាលបរិច្ឆេទនៃរបាយការណ៍" សំដៅលើកាលបរិច្ឆេទនៃរបាយការណ៍គណនីដែលអាចផ្តល់ជូនអតិថិជន។

“បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ” សំដៅលើបញ្ញត្តិ និងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងកូនសៀវភៅនេះ និងត្រូវរាប់បញ្ចូលនូវរាល់ការកែប្រែ ការផ្លាស់ប្តូរ និងការបន្ថែមផ្សេងៗ ដែល HLBCAM ធ្វើឡើងនៅពេលណាមួយនាអនាគត ហើយបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ ត្រូវអនុវត្តចំពោះរាល់គណនីទាំងអស់ លើកលែងតែមានបញ្ញត្តិនៃគណនីជាក់លាក់ណាមួយដែលចែងផ្ទុយនឹងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ នោះបញ្ញត្តិនៃគណនីជាក់លាក់ត្រូវបានអនុវត្ត។

## ២. ការបកស្រាយ

២.១ បញ្ញត្តិ និងលក្ខខណ្ឌដែលប្រើប្រាស់លើភេទប្រុស រួមបញ្ចូលទាំងភេទស្រី និងអភេទត្រូវបកស្រាយដូចគ្នារួមទាំងករណីផ្ទុយមកវិញ ។ ពាក្យដែលប្រើប្រាស់លើឯកវចនៈ រួមបញ្ចូលទាំងពហុវចនៈត្រូវបកស្រាយដូចគ្នារួមទាំងករណីផ្ទុយមកវិញ។

២.២ ប្រសិនបើអតិថិជនមានចំនួនពីរ ឬ ច្រើននាក់ បុគ្គលម្នាក់ៗត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវដោយសាមគ្គីភាព និង ដោយឡែកពីគ្នា។

## ៣. ការបើក និងការបិទគណនី:

៣.១ ការបើកគណនី ការធ្វើប្រតិបត្តិការទូទៅ និងការបិទគណនី គឺត្រូវបានគ្រប់គ្រងដោយបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ ដែលអាចត្រូវបានបន្ថែម កែប្រែ ផ្លាស់ប្តូរ លុបចោល និងផ្លាស់ប្តូរផ្នែកខ្លះនៅពេលណាមួយនាអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ដោយមាន ឬ គ្មានការផ្តល់ដំណឹងហើយអតិថិជនយល់ព្រម និងបន្តគោរពតាមបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ និងការកែប្រែ ការផ្លាស់ប្តូរ ការលុបចោល និងការផ្លាស់ប្តូរផ្នែកខ្លះនោះ។

៣.២ ការបើកគណនីត្រូវធ្វើឡើងតាមទម្រង់បែបបទដែល HLBCAM បានកំណត់ និងស្ថិតក្រោមលក្ខខណ្ឌតម្រូវរបស់ HLBCAM ដោយរួមបញ្ចូលទាំងអាយុ ចំនួនប្រាក់តម្កល់អប្បបរមា ឯកសារយោង និងឯកសារគាំទ្រផ្សេងទៀតដែល HLBCAM អាចទទួលបាន។ នៅគ្រប់ពេលវេលា និងនៅពេលណាមួយនាអនាគត HLBCAM អាចធ្វើការកែប្រែលក្ខខណ្ឌតម្រូវទាំងនោះតាមឆន្ទានុសិទ្ធិតែមួយគត់របស់ខ្លួន។

៣.៣ HLBCAM រក្សាសិទ្ធិក្នុងការបដិសេធពាក្យស្នើសុំបើកគណនីដោយមិនចាំបាច់បង្ហាញហេតុផលណាមួយចំពោះការបដិសេធរបស់ខ្លួន ។ ការបដិសេធរបស់ HLBCAM ជាសេចក្តីសម្រេចចុងក្រោយ។

៣.៤ អតិថិជនត្រូវផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារផ្សេងទៀតដែលមានសុពលភាពដល់ HLBCAM និងដែល HLBCAM អាចតម្រូវឱ្យអតិថិជនផ្តល់ជូននៅពេលណាមួយនាអនាគត ក្នុងការបើកគណនី។ អតិថិជនត្រូវធានាថា ឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារផ្សេងទៀតត្រូវមានសុពលភាពគ្រប់ពេលវេលា និងធ្វើការជូនដំណឹងដល់ HLBCAM តាមដែលអាចធ្វើទៅបាននៅពេលដែលឯកសារខាងលើអស់សុពលភាព ដោយសារហេតុផលណាមួយ។ នៅពេលណាមួយនាអនាគត HLBCAM រក្សាសិទ្ធិក្នុងការស្នើសុំព័ត៌មាន និងឯកសារបន្ថែមដោយស្របតាមច្បាប់ ឬ ឯកសារដែលស្របទៅតាមច្បាប់ស្តីពី ការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់កម្ពុជា ឬ/និង បទបញ្ញត្តិប្រហាក់ប្រហែលផ្សេងទៀតដែលមានជាធរមាននៅក្នុង ប្រទេសកម្ពុជា និង/ឬ ប្រទេសម៉ាឡេស៊ី ហើយអតិថិជនសន្យាផ្តល់ជូន HLBCAM ភ្លាមៗចំពោះព័ត៌មាន ឬ ឯកសារខាងលើតាម និងនៅពេលដែលបានស្នើសុំ។

៣.៥ អតិថិជនត្រូវធានាថា រាល់ព័ត៌មានលម្អិតដែលមាននៅក្នុងប័ណ្ណដាក់ប្រាក់ត្រូវបានបំពេញគ្រប់ជ្រុងជ្រោយត្រឹមត្រូវ និងជាក់លាក់មុនពេលធ្វើការដាក់ប្រាក់។ គ្មានការកោសលុបត្រូវបានអនុញ្ញាតិនៅលើប័ណ្ណនោះឡើយ ហើយអតិថិជនត្រូវបំពេញប័ណ្ណដាក់ប្រាក់សារជាថ្មីដើម្បីដំណើរប្រតិបត្តិការឡើងវិញ ។ HLBCAM រក្សាសិទ្ធិក្នុងការកែប្រែ ឬ លុបរាល់ព័ត៌មានដែលបានបំពេញរួចនៅលើប័ណ្ណដាក់ប្រាក់នោះក្នុងករណីមានកំហុសតូចតាចកើតឡើង។

៣.៦ តាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM អាចបិទគណនីដោយជូនដំណឹងជាមុនទៅដល់ ម្ចាស់គណនីអំពីការបិទគណនីនោះ ហើយ HLBCAM ពុំមានកាតព្វកិច្ចបង្ហាញហេតុផលណាមួយចំពោះការបិទនេះឡើយ។

៣.៧ លើកលែងតែ HLBCAM យល់ព្រមផ្សេងពីនេះ ការបិទគណនីដោយម្ចាស់គណនីត្រូវធ្វើឡើងដោយម្ចាស់គណនីផ្ទាល់ ដោយធ្វើការបំពេញទម្រង់បែបបទដែលកំណត់ដោយ HLBCAM។

៣.៨ បន្ទាប់ពីការបិទគណនីណាមួយ ឬ ទាំងអស់ ទោះបីដោយម្ចាស់គណនី ឬ ដោយ HLBCAM អតិថិជនត្រូវប្រគល់ត្រលប់មក HLBCAM វិញភ្លាមៗ រាល់មូលប្បទានប័ត្រដែលមិនទាន់ប្រើប្រាស់ប័ណ្ណអេធីអឹម ( ATM) និងវត្ថុផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងគណនីដែល HLBCAM បានផ្តល់ជូនអតិថិជន។

៣.៩ នៅពេលម្ចាស់គណនីធ្វើការដកប្រាក់សមតុល្យទាំងអស់ពីគណនីរបស់ខ្លួននោះ គណនីនោះត្រូវបានសន្មត់ថាបានបិទ។

**៤. <u>ភាពគ្រប់គ្រាន់នៃមូលនិធិ:</u>** អតិថិជនត្រូវធានាថាមានទឹកប្រាក់គ្រប់គ្រាន់ និងច្បាស់លាស់នៅក្នុងគណនីសម្រាប់ដំណើរប្រតិបត្តិការណាមួយ ដែលត្រូវបានធ្វើឡើងដោយអតិថិជន។ ការបិទគណនី នឹងត្រូវធ្វើឡើងដោយម្ចាស់គណនីផ្ទាល់ដោយដាក់ពាក្យស្នើសុំតាមទម្រង់បែបបទដែលកំណត់ដោយ HLBCAM ។

## ៥. <u>ការផ្តល់សេចក្តីណែនាំ និងការជូនដំណឹង:</u>

៥.១ អតិថិជនសន្យាជូនដំណឹងជាលាយលក្ខណ៍អក្សរមក HLBCAM ឱ្យបានឆាប់តាមតែអាចធ្វើបានអំពីសេចក្តីណែនាំនានា ឬ ការផ្លាស់ប្តូរទាំងឡាយទៅលើឯកសារយោង ដោយរួមបញ្ចូលតែមិនកម្រិតត្រឹមហត្ថលេខាមួយ/ច្រើន អាសយដ្ឋាន ឬ ព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជន ឬ ក្រុមហ៊ុន។ HLBCAM មិនទទួលខុសត្រូវលើការបាត់បង់ដែលកើតឡើងចំពោះអតិថិជន ដោយសារការផ្លាស់ប្តូរដែលមិនមានការជូនដំណឹងច្បាស់លាស់មក HLBCAM ឡើយ។ HLBCAM មិនទទួលខុសត្រូវចំពោះការពន្យាពេល ឬ ការលុបចោលចំពោះដំណើរប្រតិបត្តិការតាមសេចក្តីណែនាំនោះឡើយ។

៥.២ រាល់សេចក្តីណែនាំ និងការជូនដំណឹងមក HLBCAM ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ នឹងត្រូវបានចាត់ទុកថាបានបញ្ជូនដល់ HLBCAM នៅពេល HLBCAM បានបញ្ជាក់ជាលាយលក្ខណ៍អក្សរថាបានទទួល។ រាល់ការទាមទារ ឬ ការជូនដំណឹងទៅកាន់ម្ចាស់គណនីដែលត្រូវបានធ្វើឡើងដោយ HLBCAM នឹងត្រូវចាត់ទុកថាបានបញ្ជូនដល់ ប្រសិនបើត្រូវបានបញ្ជូនដោយផ្ទាល់ដៃ ឬ បន្ទាប់ពីបានផ្ញើតាមប្រៃសណីយ៍ទៅកាន់អាសយដ្ឋានចុងក្រោយរបស់ម្ចាស់គណនីដែល HLBCAM បានដឹងនិងដែលមានតម្កល់នៅ HLBCAM។

**៦. <u>សិទ្ធិក្នុងការទូទាត់ និងបូកបញ្ចូលគ្នា:</u>** ដោយមិនយោងតាមវិធានការដោះស្រាយណាមួយផ្សេងទៀត ដែល HLBCAM មាន HLBCAM មានសិទ្ធិក្នុងការបង្រួម និងបូកបញ្ចូលគណនីណាមួយ ឬ ទាំងអស់របស់អតិថិជនដែលបានបើក និងមានជាមួយ HLBCAM ទោះបីជាក្នុងទម្រង់បែបណាក៏ដោយដែលរួមទាំង តែមិនកម្រិតត្រឹមគណនីរួមគ្នា ឬ គណនីប្រាក់បញ្ញើមានកាលកំណត់ ដែលជាបំណុលរបស់អតិថិជនមានជាមួយ HLBCAM ហើយ HLBCAM មានសិទ្ធិទូទាត់សមតុល្យសរុបជាមួយនឹងបំណុលខាងលើដែលដល់កាលបរិច្ឆេទ ត្រូវទូទាត់ប៉ុន្តែមិនទាន់បានធ្វើការទូទាត់សង។

**៧. <u>ការចំណាយ និងថ្លៃសេវា:</u>** ស្ថិតក្រោមលក្ខខណ្ឌនៃចំណុច៦ខាងលើ HLBCAM មានសិទ្ធិកំណត់កម្រៃ សេវា និងថ្លៃសេវាផ្សេងៗទៀត និងការពិន័យ ដោយរួមបញ្ចូលទាំងកម្រៃសេវាទូទៅរបស់ HLBCAM កម្រៃជើងសារពន្ធប្រថាប់ត្រានៅលើគ្រប់ប្រតិបត្តិការទាំងអស់ និងសេវាកម្មដែលត្រូវបានផ្តល់ជូនតាមអត្រាណាមួយ ដែលត្រូវ

អាចជូនដំណឹងនៅពេលណាមួយនាអនាគត ។ HLBCAM រក្សាសិទ្ធិជាដាច់ខាតក្នុងការកែប្រែថ្លៃសេវាកម្ម និងការពិន័យដូចរៀបរាប់ខាងលើនៅគ្រប់ពេលវេលា និងនៅពេលណាមួយនាអនាគតដោយធ្វើការជូនដំណឹងជាមុន។

៨. **<u>ការហាមឃាត់ចំពោះការបង្កើតសិទ្ធិប្រាតិភោគ:</u>** គណនីដែលត្រូវបានបើក និងមាននៅ HLBCAM រួមទាំងឯកសារពាក់ព័ន្ធទាំងអស់ផងដែរ ដោយរាប់បញ្ចូលប៉ុន្តែមិនកំណត់ត្រឹម សៀវភៅគណនីបញ្ញើប្រាក់សន្សំ និងបង្កាន់ដៃទទួលប្រាក់ ដែលចេញដោយ HLBCAM ទាក់ទងនឹងគណនីនោះ មិនត្រូវបានអនុញ្ញាតិឱ្យយកមកប្រើប្រាស់ជាប្រាតិភោគធានាកាតព្វកិច្ច ទោះបីក្នុងទម្រង់បែបណាក៏ដោយ ថាតើដោយចុះ ឬ មិនចុះបញ្ជីដោយម្ចាស់គណនីដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពី HLBCAM ឡើយ។ HLBCAM រក្សាសិទ្ធិក្នុងការដកហូតទុកការយល់ព្រម នោះដោយគ្មានកាតព្វកិច្ចក្នុងការផ្តល់ជូនហេតុផលណាមួយចំពោះការបដិសេធខាងលើឡើយ។

៩. **<u>មរណភាព និងអសមត្ថភាព:</u>** ក្នុងករណីមរណភាព ឬ អសមត្ថភាពនៃម្ចាស់គណនី ដោយរាប់បញ្ចូលទាំងគណនីរួម (ដោយមិនគិតទៅលើលក្ខខណ្ឌដំណើរការនៃគណនីដែលបានជ្រើសរើស) HLBCAM មានសិទ្ធិក្នុងការទប់ស្កាត់ដំណើរប្រតិបត្តិការរបស់គណនីនោះ រហូតដល់ការជម្រះបញ្ជីមួយ ត្រូវបានធ្វើឡើងស្របតាមច្បាប់ជាធរមាននៃម្ចាស់គណនីដែលបានទទួលមរណភាព ឬ ក្លាយជាអសមត្ថជន ។ HLBCAM រក្សាសិទ្ធិក្នុងការអនុវត្តទៅតាម លក្ខខណ្ឌតម្រូវការតាមផ្លូវច្បាប់ជាធរមាន នៅមុនពេលធ្វើការបញ្ចេញនូវសមតុល្យណាមួយនៅក្នុងគណនីទៅអ្នកតំណាងស្របច្បាប់របស់ម្ចាស់គណនី ដែលបានទទួលមរណភាព ឬ ក្លាយជាអសមត្ថជន។

១០. **<u>គណនីអសកម្ម:</u>** គណនីដែលត្រូវបានបើក និងមាននៅ HLBCAM ដែលគ្មានប្រតិបត្តិការក្នុងកំឡុងរយៈពេលមួយ (០១) ឆ្នាំត្រូវចាត់ទុកជាគណនីអសកម្ម ។ ដើម្បីដំណើរការគណនីនេះឡើងវិញម្ចាស់គណនីត្រូវធ្វើប្រតិបត្តិការដាក់/ដកប្រាក់ នៅសាខាណាមួយដែលគណនីនោះត្រូវបានបើក ។ HLBCAM រក្សាសិទ្ធិក្នុងការបិទគណនីដែលអសកម្មណាមួយ ហើយសមតុល្យដែលមិនត្រូវបានទាមទារស្របតាមបទបញ្ញត្តិជាធរមាន នឹងត្រូវផ្ទេរទៅធនាគារជាតិ នៃកម្ពុជា។

១១. **<u>ការលះបង់សិទ្ធិ:</u>** រាល់ការបង្អង់ ឬ ការខកខាន ឬ ការពន្យាពេលដោយ HLBCAM ក្នុងការអនុវត្តសិទ្ធិ ឬ អំណាច ឬ វិធានការដោះស្រាយ ឬ ការអនុវត្តដោយផ្នែកនៃសិទ្ធិ ឬ អំណាច ឬ វិធានការដោះស្រាយ ណាមួយនោះមិនត្រូវបានចាត់ទុកថាជាការលះបង់នូវសិទ្ធិ ឬ អំណាច ឬ វិធានការដោះស្រាយ និងមិនត្រូវបាន រារាំងការអនុវត្តចំពោះសិទ្ធិ ឬ អំណាច ឬ វិធានការដោះស្រាយនៅពេលក្រោយនោះឡើយ។ សិទ្ធិ និងអំណាច និងវិធានការដោះស្រាយរបស់ HLBCAM ត្រូវបន្តមានសុពលភាព និងអានុភាពដោយពេញលេញ រហូតដល់សិទ្ធិជាក់លាក់ ទាំងនោះត្រូវបាន HLBCAM បោះបង់តាមលិខិតុបករណ៍ជាលាយលក្ខណ៍អក្សរ។

១២. **<u>ការជួសជុលសំណង:</u>**

១២.១ អតិថិជនយល់ព្រមដោយគ្មានលក្ខខណ្ឌ និងមិនកែប្រែក្នុងការជួសជុលសំណងចំពោះ HLBCAM និងធានាឱ្យ HLBCAM រួចផុតពីរាល់ការទាមទារ ការស្នើ វិធានការ ការទទួលខុសត្រូវ ការខូចខាត ការចំណាយ ការខាតបង់ និងរាល់សោហ៊ុយទោះក្នុងលក្ខណៈណាក៏ដោយដែល HLBCAM អាចនឹងទទួលរងដោយវិធីណាមួយ ទាក់ទងនឹងការផ្តល់ឧបករណ៍ឥណទានធនាគារណាមួយ ឬ ប្រាក់ឱ្យខ្ចីក្នុងរយៈពេលខ្លី ឬ ការផ្តល់ជូននូវសេវាកម្មធនាគារណាមួយដល់អតិថិជន ការទូទាត់ ឬ ទទួលមូលប្បទានប័ត្រ ឬ ឧបករណ៍ផ្សេងទៀត ជួសមុខឱ្យអតិថិជនក្នុងករណីគណនីប្រាក់បញ្ញើសន្សំ ឬ គណនីណាមួយផ្សេងទៀតរបស់អតិថិជន (បំណុលរបស់ HLBCAM) និងដោយមិនកម្រិតចំពោះអ្វីដែលបានរៀបរាប់ត្រូវទូទាត់ទៅឱ្យ HLBCAM លើចំនួនទឹកប្រាក់ដែលត្រូវបានទាមទារពី HLBCAM ឬ ដែល HLBCAM អាចនឹងទូទាត់ ឬ បានក្លាយជាអ្នក ទទួលទូទាត់សងដោយអនុលោមតាម ឬ ដោយមូលហេតុ ឬ ទាក់ទងបំណុលរបស់ HLBCAM ។

១២.២ HLBCAM ត្រូវទូទាត់សងភ្លាមៗចំពោះរាល់ចំនួនណាមួយ ឬ ចំនួនទាំងអស់ដែលត្រូវបានទាមទារពីខ្លួន ឬ ចំនួនណាមួយ ឬ ចំនួនទាំងអស់ដែល HLBCAM អាចក្លាយជាអ្នកទទួលទូទាត់សង អនុលោមតាម ឬ ទាក់ទងបំណុលរបស់ HLBCAM ដោយមិនចាំបាច់មានសំអាងណាមួយ ឬ ការសម្រេចបន្ថែមទៀតពីអតិថិជន និងមិនមែនជាកាតព្វកិច្ចក្នុងការបញ្ជាក់ថាការទាមទារណាមួយចំពោះ HLBCAM នោះត្រូវបានគេធ្វើឡើងត្រឹមត្រូវនោះទេ បើទោះបីជាអតិថិជនធ្វើការជំទាស់ទៅលើភាពត្រឹមត្រូវនៃការទាមទារណាមួយក៏ដោយ ហើយអតិថិជនត្រូវទទួលយល់ព្រមចំពោះការទាមទារណាមួយ និងការទូទាត់សងដែលត្រូវបានធ្វើចំពោះ HLBCAM និងបានទូទាត់ដែលត្រូវបានធ្វើឡើងដោយ HLBCAM គឺមានសុពលភាពចំពោះអតិថិជន។ ចំនួនដែល HLBCAM បានទូទាត់ត្រូវដកចេញពីគណនីណាមួយ ឬ គណនីរួមគ្នាដែលអតិថិជនមានជាមួយ HLBCAM ។

**១៣. ករណីប្រធានសក្តិ:** ទោះបីជាមានបញ្ញត្តិណាមួយផ្សេងទៀតនៅក្នុងនេះនៅក្នុងករណីដែល HLBCAM មិនអាចមានលទ្ធភាពអនុវត្តប្រតិបត្តិការ ឬ ផ្តល់សេវាកម្ម បណ្តាលមកពីហេតុផលណាមួយលើសពីការគ្រប់គ្រងរបស់ HLBCAM រួមបញ្ចូលទាំងប៉ុន្តែមិនកំណត់ត្រឹមគ្រោះអគ្គិភ័យ រញ្ជួយផែនដី ទឹកជំនន់ ជម្ងឺឆ្លង មហន្តរាយធម្មជាតិ គ្រោះថ្នាក់ បាតុកម្ម ចលាចលសង្គម វិវាទឧស្សាហកម្ម ការដាក់ទណ្ឌកម្ម សង្គ្រាម ឬ គ្រោះធម្មជាតិ ឬ កត្តាណាមួយក្នុងលក្ខណៈជាប្រធានសក្តិ ឬ ការខកខាន ឬ ការកាត់ផ្តាច់ការផ្គត់ផ្គង់ផ្នែកទូរគមនាគមន៍ ប្រព័ន្ធអគ្គីសនី ទឹក ប្រេងឥន្ធនៈ HLBCAM មិនទទួលខុសត្រូវទោះក្នុងទម្រង់ណាក៏ដោយ ចំពោះផលវិបាក ការបាត់បង់ ការខូចប្រយោជន៍ ការខូចខាតដែលអតិថិជនទទួលរង ឬ កើតមានទេ។

**១៤. ការបញ្ចេញព័ត៌មាន:** អតិថិជនយល់ព្រម និងអនុញ្ញាតឱ្យ HLBCAM បញ្ចេញព័ត៌មានរបស់អតិថិជនទៅបុគ្គលណាម្នាក់នៅក្នុង ឬ ក្រៅប្រទេសកម្ពុជារួមទាំងប៉ុន្តែមិនកំណត់ត្រឹមចំពោះក្រុមហ៊ុនទាំងឡាយនៅក្នុងក្រុមនៃHLBCAM រួមទាំងក្រុមហ៊ុនមេនៃ HLBCAM ទោះបីជាក្រុមហ៊ុនទាំងនោះមានស្នាក់ការចុះបញ្ជី ឬ មានទីតាំង ឬ ប្រកបអាជីវកម្ម ចុះបញ្ជីពាណិជ្ជកម្ម ឬ បង្កើតឡើងនៅក្នុង ឬ នៅក្រៅប្រទេសកម្ពុជាក៏ដោយ ។ បន្ថែមពីនេះ អតិថិជនអនុញ្ញាតិឱ្យបញ្ចេញរួមទាំងប៉ុន្តែមិនកំណត់ត្រឹមព័ត៌មានពាក់ព័ន្ធនឹងអតិថិជន ឬ ការងាររបស់អតិថិជន និង/ឬ គណនីធនាគារដែល HLBCAM យល់ឃើញថាសមស្របសម្រាប់គោលបំណងនោះ។ ការបញ្ចេញព័ត៌មានទៅកាន់ក្រុមហ៊ុន ដែលមានពាក់ព័ន្ធនៅក្នុងការផ្សព្វផ្សាយ ជម្រុញការលក់ ការផ្គត់ផ្គង់ និងបែងចែកផលិតផល និងសេវាកម្មហិរញ្ញវត្ថុគឺត្រូវបានធ្វើឡើងដើម្បីងាយស្រួលដល់ប្រតិបត្តិការអាជីវកម្ម ការផ្គត់ផ្គង់ទៅវិញទៅមក និងគោលបំណងផ្សេងទៀតរបស់ HLBCAM ។

**១៥. សុវត្ថិភាព និងការបដិសេធការទទួលខុសត្រូវ:** បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវ/សេចក្តីណែនាំចំពោះអតិថិជនទាក់ទងលើបញ្ហាសុវត្ថិភាពនៃគណនីរបស់អតិថិជន ឬ គណនីដែលពាក់ព័ន្ធ នឹងឧបករណ៍ និងកំណត់ត្រាដែលទាក់ទងនឹងគណនី។ ក្នុងករណីដែលបញ្ញត្តិ/លក្ខខណ្ឌ/សេចក្តីណែនាំដែលបាន ចែងនៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ មិនត្រូវបានអនុវត្តតាមដោយអតិថិជន HLBCAM មិនត្រូវបានដាក់ឱ្យទទួលខុសត្រូវទាំងអស់ចំពោះផ្នែកដែលទាក់ទងនឹងការមិនគោរពតាមបញ្ញត្តិ/លក្ខខណ្ឌ /សេចក្តីណែនាំនោះ ។ អតិថិជនយល់ និងដឹងថាក្នុងករណីដែលការប្រើប្រាស់គណនីដោយបុគ្គលច្រើនរូប អតិថិជនត្រូវបញ្ជាក់ពីតម្រូវការ នៃការការពារផ្ទៃក្នុង រវាងអ្នកប្រើប្រាស់ និងការត្រួតពិនិត្យរបាយការណ៍គណនីចរន្ត ដូចដែលមានចែងក្នុងនេះ។

**១៦. ស្វ័យភាពនៃបញ្ញត្តិ:** បើសិនជាអាចធ្វើបាន រាល់បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះត្រូវបានបកស្រាយទៅតាមលទ្ធភាព ដែលអាចឱ្យវាមានសុពលភាព និងប្រសិទ្ធិភាពស្របតាមបញ្ញត្តិច្បាប់ដែលមានជាធរមាន ។ ក៏ប៉ុន្តែ ក្នុងករណីដែល បញ្ញត្តិ និងលក្ខខណ្ឌណាមួយមិនអាចអនុវត្តបាន ឬ គ្មានសុពលភាពស្របតាមច្បាប់ជាធរមាន អសុពលភាព ឬ ភាពគ្មានប្រសិទ្ធិភាពនោះ មិនប៉ះពាល់ដល់បញ្ញត្តិ និងលក្ខខណ្ឌដទៃទៀតនោះឡើយ ហើយបញ្ញត្តិ និងលក្ខខណ្ឌដទៃទៀតនោះនៅតែបន្តអនុវត្ត និងមានសុពលភាពពេញលេញ។

**១៧. ច្បាប់:** បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះត្រូវគ្រប់គ្រង និងបកស្រាយស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាធរមាន ។ រាល់វិវាទណាមួយដែលកើតចេញពីបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះត្រូវបញ្ជូនទៅតុលាការ ដែលមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

# ផ្នែកទី ២ គណនី

## ១. គណនីបញ្ញើប្រាក់សន្សំ

១.១ គណនីបញ្ញើប្រាក់សន្សំត្រូវបានបង្កើតឡើងសម្រាប់អតិថិជន ដែលមានបំណងសន្សំប្រាក់តាមពេលវេលាទៀងទាត់មួយ សម្រាប់អនាគត។

១.២ អតិថិជនអាចដាក់ប្រាក់បញ្ញើទៅក្នុងគណនីបញ្ញើប្រាក់សន្សំដោយបំពេញទម្រង់បែបបទដែល HLBCAM បានកំណត់ ហើយប្រគល់ឯកសារយោងជូន HLBCAM តាមសាខាណាមួយរបស់ HLBCAM។

១.៣ បន្ទាប់ពីការបើកគណនីបញ្ញើប្រាក់សន្សំ HLBCAM នឹងផ្តល់ជាសៀវភៅគណនីបញ្ញើប្រាក់សន្សំទៅដល់អតិថិជន។

១.៤ HLBCAM មិនទទួលខុសត្រូវរាល់កំណត់ត្រា ឬ ចំនួនទឹកប្រាក់ណាមួយដែលបានចុះក្នុងសៀវភៅគណនីបញ្ញើប្រាក់សន្សំដោយមិនមានហត្ថលេខាផ្ទៀងផ្ទាត់ដោយបុគ្គលិក HLBCAM ដែលត្រូវបានទទួលការអនុញ្ញាត ឬការបញ្ជាក់ដោយម៉ាស៊ីនរបស់ HLBCAM ឡើយ។ ហេតុដូចនេះអតិថិជនត្រូវពិនិត្យមើលដោយប្រុងប្រយ័ត្ននូវរាល់ការបញ្ចូលទិន្នន័យនៅក្នុងសៀវភៅគណនីបញ្ញើប្រាក់សន្សំមុនពេលចាកចេញពីបរិវេណ HLBCAM ។

១.៥ HLBCAM អាចកំណត់លក្ខខណ្ឌ ប៉ុន្តែមិនកំណត់ត្រឹម ចំនួនទឹកប្រាក់បញ្ញើលើកដំបូងសម្រាប់ការបើកគណនីប្រាក់បញ្ញើប្រាក់សន្សំថ្មី និងកម្រិតសមតុល្យអប្បបរមា ដែលអតិថិជនត្រូវរក្សាទុកដូចមានចែងក្នុងលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗរួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ។ លក្ខខណ្ឌតម្រូវការទាំងនេះអាចនឹងត្រូវបានកែប្រែនៅពេលណាមួយនាអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ដោយមាន ឬ គ្មានការជូនដំណឹងជាមុន។

១.៦ ការប្រាក់ដែលទទួលបានពីចំនួនទឹកប្រាក់នៃការដាក់ប្រាក់បញ្ញើទៅក្នុងគណនីបញ្ញើប្រាក់សន្សំ នឹងត្រូវគណនាប្រចាំថ្ងៃជាមូលដ្ឋានទៅលើសមតុល្យដែលមានដោយគិតតាមអត្រាការប្រាក់ធម្មតារបស់ HLBCAM និងគោលការណ៍ដូចមានចែងនៅក្នុង លក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗរួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ។ ការប្រាក់ដែលទទួលបាន ត្រូវស្ថិតក្រោមលក្ខខណ្ឌនៃការអនុវត្តពន្ធជាធរមាន ហើយត្រូវដាក់បញ្ចូលទៅក្នុងគណនីបញ្ញើប្រាក់សន្សំនោះរៀងរាល់ថ្ងៃចុងក្រោយបង្អស់នៃខែ ឬថ្ងៃផ្សេងទៀតដែល HLBCAM កំណត់ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ។ HLBCAM រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរអត្រាការប្រាក់ធម្មតាដោយមានការជូនដំណឹងជាមុនទៅអតិថិជនដូចមានចែងក្នុងលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗរួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM។

១.៧ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅ HLBCAM ក្នុងករណីដែលបាត់សៀវភៅគណនីបញ្ញើប្រាក់សន្សំ ។ សៀវភៅគណនីបញ្ញើប្រាក់សន្សំថ្មីអាចនឹងត្រូវផ្តល់ជូនអតិថិជនតាមការស្នើសុំរបស់អតិថិជនដោយការចំណាយជាបន្ទុករបស់អតិថិជន ក្នុងលក្ខខណ្ឌដែលអតិថិជនបានចុះហត្ថលេខាលើលិខិតធានា ជួសជុលសំណង តាមទម្រង់ដែលកំណត់ដោយ HLBCAM។ HLBCAM មិនទទួលខុសត្រូវចំពោះរាល់ការបាត់បង់ ឬ ការខូចខាតណាមួយ ដែលម្ចាស់គណនីទទួលរង ដែលបណ្តាលមកពីការធ្វេសប្រហែស ដោយម្ចាស់គណនី ក្នុងករណីមានការបន្លំដកប្រាក់ពីគណនីបញ្ញើប្រាក់សន្សំ នៅមុនពេល HLBCAM ទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរនៃការបាត់សៀវភៅគណនីបញ្ញើប្រាក់សន្សំ ។

១.៨ ការដកប្រាក់អាចត្រូវបានធ្វើឡើងដោយម្ចាស់គណនីផ្ទាល់ ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ សៀវភៅគណនីបញ្ញើប្រាក់សន្សំ និងបំពេញទម្រង់បែបបទដកប្រាក់ដូច HLBCAM បានកំណត់ និង ឯកសារពាក់ព័ន្ធផ្សេងទៀតឱ្យបានត្រឹមត្រូវ តាមដែល HLBCAM ស្នើសុំ និង HLBCAM បានផ្ទៀងផ្ទាត់ដោយត្រឹមត្រូវលើឯកសារទាំងនោះ។ រាល់ការទូរទាត់ដែល HLBCAM ធ្វើឡើងចំពោះអ្នកកាន់សៀវភៅគណនីបញ្ញើប្រាក់សន្សំ និងមានប័ណ្ណដកប្រាក់ដែលត្រូវបានអះអាងថាចុះហត្ថលេខាដោយអតិថិជន ត្រូវមានអនុភាពដូចដែលធ្វើឡើងដោយអតិថិជនផ្ទាល់ខ្លួន និងត្រូវឱ្យ HLBCAM និងបុគ្គលិករបស់ HLBCAM រួចផុតពីការទទួលខុស ត្រូវចំពោះអតិថិជន ឬ បុគ្គលណាមួយផ្សេងទៀត។

## ២. <u>គណនីអាជីវកម្មទទួលបានការប្រាក់:</u>

២.១ គណនីអាជីវកម្មទទួលការប្រាក់ គឺជាគណនីបញ្ញើប្រាក់សន្សំ ដែលបង្កើតឡើងសម្រាប់អតិថិជនមិនមែនជារូបវ័ន្តបុគ្គល ដែលមានបំណងទទួលបានការប្រាក់ទៅលើមូលនិធិដែលបានដាក់បញ្ញើនៅ HLBCAM សម្រាប់រយៈពេលណាមួយមិនជាក់លាក់។

២.២ HLBCAM អាចកំណត់លក្ខខណ្ឌ ដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំនួនទឹកប្រាក់បញ្ញើលើកដំបូង កម្រៃសេវាកម្ម និងកម្រិតសមតុល្យអប្បបរមាដែលអតិថិជនត្រូវរក្សាទុក សម្រាប់បើកគណនីអាជីវកម្ម ទទួលបានការប្រាក់ ដូចមានចែងក្នុង លក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ ដែលមាននៅតាមសាខា HLBCAM។ លក្ខខណ្ឌតម្រូវការទាំងនេះអាចនឹងត្រូវបានកែប្រែនៅពេលណាមួយ នាអនាគតតាម ឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ដោយមាន ឬ គ្មានការជូនដំណឹងជាមុន។

២.៣ អតិថិជននឹងត្រូវទទួលការពិន័យ ដូចមានចែងក្នុង លក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗរួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ក្នុងករណីដែលសមតុល្យនៃគណនីអាជីវកម្មទទួលបានការប្រាក់មានចំនួនតិចជាងចំនួនដែលត្រូវបានកំណត់ដោយលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ។

២.៤ អតិថិជនអាចធ្វើការដាក់ ឬ ដកប្រាក់ពីគណនីអាជីវកម្មទទួលបានការប្រាក់ ស្របទៅតាមលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ដោយបំពេញទម្រង់បែបបទស្នើសុំដែល HLBCAM បានកំណត់។

២.៥ របាយការណ៍សមតុល្យនៃគណនីអាជីវកម្មទទួលបានការប្រាក់ នឹងត្រូវផ្តល់ជូនអតិថិជនស្របតាមលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ឬក្នុង កំឡុងពេលណាមួយតាមការកំណត់របស់ HLBCAM តាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ។

២.៦ អតិថិជនត្រូវពិនិត្យមើលនូវរាល់ទិន្នន័យនៅក្នុងរបាយការណ៍សមតុល្យគណនីអាជីវកម្មទទួលបានការប្រាក់ ឬ ក្នុងករណីអតិថិជនប្រើប្រាស់សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM របាយការណ៍គណនីអេឡិចត្រូនិច (on-line) និងត្រូវជូនដំណឹងមក HLBCAM ភ្លាមក្នុងករណី ដែលរកឃើញថាមានកំហុសកើតឡើងនៅក្នុងនោះ។ ក្នុងកំឡុងពេល ១៤ថ្ងៃ (ឬ ក្នុងរយៈពេលជាក់លាក់ណាមួយកំណត់ដោយ HLBCAM) ប្រសិនបើអតិថិជនមិនធ្វើការជូនដំណឹងអំពីការជំទាស់លើទិន្នន័យណាមួយបន្ទាប់ពីទទួលបានរបាយការណ៍គណនីអាជីវកម្មទទួលបានការប្រាក់ ឬ ពីកាលបរិច្ឆេទរបាយការណ៍គណនីអេឡិចត្រូនិច (on-line) អតិថិជនត្រូវបានសន្មត់ថាបានទទួលយកទិន្នន័យនោះថា ត្រឹមត្រូវគិតត្រឹមថ្ងៃបញ្ចូលចុងក្រោយនៅក្នុងរបាយការណ៍គណនីអាជីវកម្មទទួលបានការប្រាក់ ឬ របាយការណ៍គណនី អេឡិចត្រូនិច (on-line) សម្រាប់អតិថិជនប្រើប្រាស់សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM និងធានាឱ្យ HLBCAM រួចផុតពីការទទួលខុសត្រូវទាំងអស់។

## ៣. គណនីចរន្ត:

៣.១ គណនីចរន្ត គឺជាប្រភេទគណនីប្រតិបត្តិការដែលបង្កើតឡើងសម្រាប់អតិថជនដែលមានតម្រូវការលើសេវាកម្មដែលមានភាពងាយស្រួល និងអាចប្រើប្រាស់មូលនិធិរបស់ខ្លួន ។

៣.២ អតិថិជនអាចដាក់ប្រាក់បញ្ញើទៅក្នុងគណនីចរន្តដោយបំពេញទម្រង់បែបបទដែល HLBCAM បានកំណត់ និងត្រូវផ្ដល់ឯកសារ HLBCAM បានកំណត់នៅតាមសាខាណាមួយរបស់ HLBCAM ។

៣.៣ HLBCAM អាចកំណត់លក្ខខណ្ឌ ដែលរួចមកប៉ុន្តែមិនកំណត់ត្រឹម ចំនួនទឹកប្រាក់បញ្ញើលើកដំបូង កម្រៃសេវាកម្ម និងកម្រិតសមតុល្យអប្បបរមាដែលអតិថិជនត្រូវរក្សាទុក សម្រាប់បើកគណនីចរន្ត ដូចមានចែងក្នុងលក្ខណៈ សំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM។ លក្ខខណ្ឌតម្រូវការទាំងនេះអាចនឹងត្រូវបានកែប្រែនៅពេលណាមួយនាអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ដោយមាន ឬ គ្មានការជូនដំណឹងជាមុន។

៣.៤ អតិថិជនត្រូវដាក់ពាក្យស្នើសុំសៀវភៅមូលប្បទានប័ត្រ ជាលាយលក្ខ័អក្សរតាមទម្រង់បែបបទដែល HLBCAM បានកំណត់ ឬ តាមមធ្យោបាយណាមួយផ្សេងទៀត ដែល HLBCAM បានអនុញ្ញាត ។ បន្ទាប់ពីអតិថិជនបានបំពេញរាល់លក្ខខណ្ឌតម្រូវការដែល HLBCAM បានកំណត់ តាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM អតិថិជន នឹងត្រូវបានជូនដំណឹងអំពីភាពរៀបរយនៃសៀវភៅមូលប្បទានប័ត្រដែលអតិថិជនអាចទទួលបានដោយខ្លួន ឯងផ្ទាល់នៅសាខា HLBCAM ដែលអតិថិជនបើកគណនីចរន្តនោះ ។ អតិថិជនអាចស្នើសុំសៀវភៅមូលប្បទានប័ត្រលើកបន្តបន្ទាប់ ដោយប្រើប្រាស់ទំព័រសម្រាប់ស្នើសុំដែលមានស្រាប់នៅក្នុងសៀវភៅមូលប្បទានប័ត្រចាស់នោះ នៅពេលដែលអតិថិជនពេញចិត្តប្រតិបត្តិការរបស់គណនីចរន្តនោះ។

៣.៥ មានតែមូលប្បទានប័ត្រដែលត្រូវបានផ្ដល់ជូនដោយ HLBCAM ដោយមាននូវលេខគណនីចរន្តរបស់ HLBCAM តែប៉ុណ្ណោះ ដែលអាចប្រើប្រាស់សម្រាប់បើកប្រាក់ពី HLBCAM ។ អតិថិជនត្រូវស្នើសុំការអនុញ្ញាតិពី HLBCAM ជាមុនក្នុងករណីមានបំណងដកសាច់ប្រាក់ដោយប្រើប្រាស់មូលប្បទានប័ត្រ ឬ ប័ណ្ណដកប្រាក់ដែលបានកំណត់ ឬ ឧបករណ៍ផ្សេងទៀត ឬទម្រង់បែបបទផ្សេងទៀតដែល HLBCAM បានកំណត់ ។ មិនត្រូវប្រើប្រាស់ម៉ាស៊ីនវាយអក្សរអេឡិចត្រូនិច/អង្គុលីលេខអេឡិចត្រូនិច និងប៊ិចដែលទឹកថ្នាំអាចលុបបានដើម្បីសរសេរលើមូលប្បទានប័ត្រនោះទេ។ HLBCAM មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬ ការខូចខាតណាមួយ ដែលបណ្ដាលមកពីការប្រើប្រាស់ម៉ាស៊ីនវាយអក្សរអេឡិចត្រូនិច/អង្គុលីលេខអេឡិចត្រូនិច និងប៊ិច ដែលទឹកថ្នាំអាចលុបបានឡើយ។

៣.៦ អតិថិជននឹងត្រូវយកចិត្តទុកដាក់ចំពោះការសរសេរមូលប្បទានប័ត្រ ដែលមិនបង្កអោយមានការក្លែងបន្លំ។ HLBCAM មានសិទ្ធិក្នុងការមិនទទួលទូទាត់ និងបញ្ជូនត្រលប់ទៅវិញ ក្នុងករណីដែលហត្ថលេខារបស់អតិថិជនខុសពីគំរូហត្ថលេខាដែលផ្ដល់មក HLBCAM។ មិនត្រូវមានការកែប្រែផ្លាស់ប្ដូរណាមួយនៅលើមូលប្បទានប័ត្រនោះទេ ។ HLBCAM រក្សាសិទ្ធិក្នុងការមិនទូទាត់ និងបញ្ជូនត្រលប់ទៅវិញនូវមូលប្បទានប័ត្រណាមួយ ដែលក្នុងការយល់ឃើញរបស់ HLBCAM មានការកែប្រែផ្លាស់ប្ដូរក្នុងទម្រង់ ណាមួយនោះ (ទោះមានចុះហត្ថលេខាបញ្ជាក់ដោយអតិថិជន/បហារ៉ក/ផ្សេងពីនេះ) ឬ HLBCAM មាន ហេតុផលក្នុងការសង្ស័យលើភាពត្រឹមត្រូវនៃអត្តសញ្ញាណរបស់អតិថិជន។

៣.៧ អតិថិជនត្រូវជូនដំណឹងមកកាន់ HLBCAM ជាបន្ទាន់ ក្នុងករណីដែលសៀវភៅ ឬ សន្លឹកមូលប្បទានប័ត្រណាមួយត្រូវបានបាត់ ឬ ត្រូវបានលួច ឬ ត្រូវបានបំផ្លាញ។ HLBCAM មិនទទួលខុសត្រូវទៅលើការ បាត់បង់ ឬ ការខូចខាតដែលអតិថិជនទទួលរងនោះទេ ដែលតាមរយៈភាពធ្វេសប្រហែស ឬ កំហុស របស់អតិថិជន បុគ្គលដែលមិនទទួលបានការអនុញ្ញាតអាចទទួលសៀវភៅ ឬ សន្លឹកមូលប្បទានប័ត្រនោះហើយប្រើប្រាស់

ដើម្បីទទួលបានការទូទាត់ដោយមិនត្រឹមត្រូវនូវចំនួនទឹកប្រាក់ណាមួយ ដែលជាកម្មសិទ្ធិរបស់អតិថិជន។

៣.៨ ក្នុងករណីដែលបាត់សៀវភៅមូលប្បទានប័ត្រ តាមការស្នើសុំដោយអតិថិជន HLBCAM អាចផ្តល់ជូននូវសៀវភៅមូលប្បទានប័ត្រថ្មីទៅអតិថិជន បន្ទាប់ពីអតិថិជនបានចុះហត្ថលេខាលើលិខិតធានាជួសជុលសំណង ហើយក្នុងករណីជាគណនីរួមគ្នា ម្ចាស់គណនីទាំងអស់ត្រូវចុះហត្ថលេខា ហើយថ្លៃសេវាកម្មនឹងត្រូវជាបន្ទុករបស់ម្ចាស់គណនី ។ បន្ទាប់ពីផ្តល់ជូនសៀវភៅមូលប្បទានប័ត្រថ្មី សៀវភៅមូលប្បទានប័ត្រចាស់ត្រូវក្លាយជាគ្មានសុពលភាព និងក្នុងករណីរកឃើញវិញ ឬ យកបានមកវិញត្រូវតែបញ្ជូនត្រលប់មក HLBCAM ជាបន្ទាន់។

៣.៩ អតិថិជនត្រូវធានាថា ព័ត៌មាននៅក្នុងសៀវភៅមូលប្បទានប័ត្រគឺត្រឹមត្រូវនៅមុនពេលចាកចេញពីបរិវេណ HLBCAM ។ ការខកខានមិនបានត្រួតពិនិត្យឱ្យបានត្រឹមត្រូវនោះត្រូវធានាអោយ HLBCAM រួចផុតពីការទទួលខុសត្រូវទាំងអស់។

៣.១០ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការបញ្ឈប់ការទូរទាត់ចំពោះមូលប្បទានប័ត្រដែលបានចេញហើយ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ HLBCAM ដើម្បីបញ្ឈប់ការទូរទាត់មូលប្បទានប័ត្រត្រូវមានបញ្ជាក់៖ លេខមូលប្បទានប័ត្រ លេខគណនី ចំនួនទឹកប្រាក់ ឈ្មោះអ្នកទទួលការទូទាត់ (អត្ថគាហក) និងកាលបរិច្ឆេទ។ HLBCAM នឹងធ្វើការកត់ត្រាចំពោះតែការស្នើឱ្យបដិសេធជាមុនក្នុងការទូទាត់លើមូលប្បទានប័ត្របន្ទាប់ពីទទួលបានលិខិតជូនដំណឹងពីម្ចាស់គណនីប៉ុណ្ណោះ។ HLBCAM មិនទទួលខុសត្រូវ ឬ ទទួលរងចំពោះការបាត់បង់ដែលអតិថិជនទទួលរង បណ្តាលមកពីការមិនយកចិត្តទុកដាក់ការធ្វេសប្រហែស ក្នុងការទប់ស្កាត់ការទូទាត់មូលប្បទានប័ត្រ។

៣.១១ HLBCAM ត្រូវបានអនុញ្ញាតឱ្យធ្វើការទូទាត់រាល់មូលប្បទានប័ត្រ រូបិយណត្តិ បញ្ជារទូទាត់ ប័ណ្ណសងតាមបញ្ជារដែលបានបញ្ជាក់ជាក់លាក់ថាដើម្បីទទួលបានការទូទាត់ការចុះហត្ថលេខា ការធ្វើស៊ីការ ការធ្វើបដិលេខ ឬ ធ្វើឡើងតាំងនាមឱ្យអតិថិជន ទោះបីជាគណនីចរន្តនោះមានសមតុល្យវិជ្ជមាន ឬ អវិជ្ជមាន ឬ ក្លាយជាការដកប្រាក់លើសចំនួនដែលមានក្នុងគណនីបន្ទាប់ពីទូទាត់ ឬ ផ្សេងពីនេះ ប៉ុន្តែមិនប៉ះពាល់ចំពោះសិទ្ធិរបស់ HLBCAM ក្នុងការបដិសេធចំពោះវិបារូបន៍ណាមួយ ។ ក្នុងករណីដែលមានសមតុល្យអវិជ្ជមាន ឬ ការដកប្រាក់លើសដោយគ្មានព្រៀងទុកជាមុនកើតមានឡើង អតិថិជនត្រូវទទួលខុសត្រូវចំពោះចំនួនសរុបទាំងនោះ។

៣.១២ ប្រសិនបើម្ចាស់គណនីចេញមូលប្បទានប័ត្រច្រើនសន្លឹក ឬ ផ្តល់សេចក្តីណែនាំសម្រាប់ធ្វើការទូរទាត់ច្រើនលើកចំពោះគណនីចរន្ត ហើយប្រសិនបើចំនួនសរុបនៃមូលប្បទានប័ត្រ ឬ សេចក្តីណែនាំសម្រាប់ធ្វើការទូរទាត់ទាំងនោះមានចំនួនលើសពីចំនួនសមតុល្យដែលមាន ឬ លើសពីចំនួនដែលបានព្រមព្រៀងជាមុនជាមួយ HLBCAM នោះ HLBCAM ត្រូវមានសិទ្ធិធ្វើការទូទាត់មូលប្បទានប័ត្រ ឬ សេចក្តីណែនាំសម្រាប់ធ្វើការទូទាត់ណាមួយ ដែលបានយកមកបង្ហាញដើម្បីធ្វើការទូទាត់មុនគេ ដោយមិនគិតពីកាលបរិច្ឆេទដែលមានលើមូលប្បទានប័ត្រ ឬ សេចក្តីណែនាំសម្រាប់ធ្វើការទូទាត់សងប្រាក់ ដោយប្រើប្រាស់មូលនិធិដែលមានក្នុងគណនីនោះ ។

៣.១៣ ក្នុងករណីដែល HLBCAM បដិសេធមិនធ្វើការទូទាត់មូលប្បទានប័ត្រណាមួយ HLBCAM អាច (តែមិនមែនជាកាតព្វកិច្ច) ប្រគល់មូលប្បទានប័ត្រនោះទៅអ្នកដែលយកមកបង្ហាញដើម្បីធ្វើការទូទាត់វិញ ដោយមាន ឬ មិនមានការផ្តល់ជូននូវមូលហេតុ ។ HLBCAM មិនទទួលខុសត្រូវចំពោះអ្នកចេញមូលប្បទានប័ត្រ អ្នកទទួលផលប្រយោជន៍ (អត្ថគាហក) ឬ តតិយភាគីណាមួយ ចំពោះការបដិសេធក្នុងការទូទាត់មូលប្បទានប័ត្រ

ដោយហេតុថា HLBCAM ធ្វើដោយសុចរិត និង ស្មោះត្រង់ ។ HLBCAM រក្សាសិទ្ធិក្នុងការធ្វើការពិន័យចំពោះការបដិសេធមិនធ្វើការទូទាត់មូលប្បទានប័ត្រតាមការកំណត់ដោយឆន្ទានុសិទ្ធិដាច់ខាតរបស់ HLBCAM នៅពេលណាមួយនាអនាគត។

៣.១៤ របាយការណ៍គណនីចរន្តនឹងត្រូវបានផ្តល់ជូនមួយលើកក្នុង១ខែ ឬ ក្នុងរយៈពេលផ្សេងតាមការកំណត់ដោយ HLBCAM ។ អតិថិជនត្រូវត្រួតពិនិត្យមើលរាល់ទិន្នន័យនៅក្នុងរបាយការណ៍គណនីចរន្តរបស់ខ្លួនឱ្យបានច្បាស់លាស់ ឬ ក្នុងករណីអតិថិជនប្រើប្រាស់សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM របាយការណ៍គណនីអេឡិចត្រូនិច (on-line) នឹងត្រូវធ្វើការជូនដំណឹងមក HLBCAM ជាបន្ទាន់ ប្រសិនបើរកឃើញថាមានកំហុសកើតឡើងនៅក្នុងនោះ។ ប្រសិនបើក្នុងកំឡុងពេល ១៤ ( ដប់បួន ) ថ្ងៃ ( ឬ រយៈពេលផ្សេងទៀតដែលកំណត់ដោយ HLBCAM នៅក្នុងរបាយការណ៍/ការជូនដំណឹង/របាយការណ៍គណនីអេឡិចត្រូនិច (on-line) បន្ទាប់ពីទទួលបានរបាយការណ៍គណនីចរន្ត ឬ ពីកាលបរិច្ឆេទនៃរបាយការណ៍គណនីអេឡិចត្រូនិច (on-line) អតិថិជនមិនបានធ្វើការជំទាស់ លើទិន្នន័យព័ត៌មានណាមួយ ដែលមាននៅក្នុងរបាយការណ៍នោះទេ អតិថិជនត្រូវបានសន្មត់ថា បានទទួលយកទិន្នន័យព័ត៌មានដែលត្រូវបានបញ្ជូនត្រឹមកាលបរិច្ឆេទនៃការបញ្ចូលចុងក្រោយនៅក្នុងរបាយការណ៍គណនីចរន្ត/ក្នុងករណីអតិថិជនប្រើប្រាស់សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM របាយការណ៍គណនីអេឡិចត្រូនិច (on-line) ត្រឹមត្រូវ និងធានាឱ្យ HLBCAM រួចផុតពីការទទួលខុសត្រូវទាំងអស់ ។

៣.១៥ អតិថិជនអាចធ្វើការបិទគណនីចរន្តដោយបំពេញពាក្យស្នើសុំជាលាយលក្ខណ៍អក្សរ ហើយដាក់ជូន HLBCAM។ HLBCAM មិនទទួលយកនូវរាល់សេចក្តីណែនាំសម្រាប់បិទគណនី ដែលបានផ្តល់ដោយផ្ទាល់មាត់ ឬ តាមមធ្យោបាយមិនមែនលាយលក្ខណ៍អក្សររាប់បញ្ចូលប៉ុន្តែមិនកំណត់ត្រឹម ទូរស័ព្ទ ទូរសារ អ៊ីម៉ែល ជាដើម។ រាល់សៀវភៅមូលប្បទានប័ត្រ ឬ មូលប្បទានប័ត្រដែលមិនទាន់បានប្រើប្រាស់ ត្រូវប្រគល់មក HLBCAM វិញភ្លាមៗ នៅពេលដែលគណនីចរន្តត្រូវបានបិទ។

## ៤. <u>គណនីចរន្តអាជីវកម្ម</u>

៤.១ គណនីចរន្តអាជីវកម្ម គឺជាប្រភេទគណនីចរន្តដែលត្រូវបានបង្កើតឡើងសម្រាប់អតិថជនមិនមែនរូបវន្តបុគ្គលដែលមានប្រតិបត្តិការញឹកញាប់ និងមានចំនួនទឹកប្រាក់ច្រើន ។

៤.២ HLBCAM អាចកំណត់លក្ខខណ្ឌដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម ចំនួនទឹកប្រាក់បញ្ញើលើកដំបូង កម្រៃសេវាកម្ម និងកម្រិតសមតុល្យអប្បបរមា ដែលអតិថិជនត្រូវរក្សាទុក សម្រាប់បើកគណនីចរន្តអាជីវកម្ម ដូចមានចែងក្នុងលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM។ លក្ខខណ្ឌតម្រូវការទាំងនេះអាចនឹងត្រូវបានកែប្រែនៅពេលណាមួយនាអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់ ដោយមាន ឬ គ្មានការជូនដំណឹងជាមុន។

៤.៣ គណនីចរន្តអាជីវកម្មត្រូវគ្រប់គ្រងដោយបញ្ញត្តិ និងលក្ខខណ្ឌដែលដូចដែលអនុវត្តចំពោះគណនីចរន្តដែរ លើកលែងបញ្ញត្តិ និង លក្ខខណ្ឌទាំងឡាយ ដែលគ្រប់គ្រងគណនីចរន្តផ្ទុយពីផ្នែក៤។

## ៥. <u>គណនីប្រាក់បញ្ញើមានកាលកំណត់</u>

៥.១ គណនីប្រាក់បញ្ញើមានកាលកំណត់ គឺជាគណនីដែលបង្កើតឡើងសម្រាប់អតិថិជនដែលមានបំណងចង់ទទួលបានចំណូលពីការប្រាក់កម្រិតខ្ពស់ ទៅលើចំនួនទឹកប្រាក់ដែលខ្លួនមាន សម្រាប់រយៈពេលជាក់លាក់ណាមួយ។

៥.២ HLBCAM អាចកំណត់លក្ខខណ្ឌដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម ចំនួនទឹកប្រាក់អប្បបរមាសម្រាប់ដាក់បញ្ញើ រយៈពេល កម្រៃសេវាកម្មសម្រាប់បើកគណនីប្រាក់បញ្ញើមានកាលកំណត់ ដូចមានចែងក្នុងលក្ខណៈសំគាល់សេវា និងកម្រៃផ្សេងៗ រួមទាំងតារាងអត្រាការប្រាក់ដែលមាននៅតាមសាខា HLBCAM ។ លក្ខខណ្ឌតម្រូវការ ទាំងនេះអាចនឹងត្រូវបានកែប្រែនៅពេលណាមួយនាអនាគតតាមឆន្ទានុសិទ្ធិតែមួយគត់របស់ HLBCAM ដោយមាន ឬ គ្មានការជូនដំណឹងជាមុន។

៥.៣ អតិថិជនអាចដាក់ប្រាក់បញ្ញើទៅក្នុងគណនីប្រាក់បញ្ញើមានកាលកំណត់ដោយបំពេញទម្រង់បែបបទដែល HLBCAM បានកំណត់ ។ បន្ទាប់ពីអតិថិជនបានបំពេញរាល់លក្ខខណ្ឌតម្រូវទាំងអស់តាមការកំណត់ដោយ HLBCAM នោះ HLBCAM នឹងផ្តល់ជូននូវវិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់ទៅអតិថិជនដែលមានការបញ្ជាក់ និងទទួលស្គាល់ត្រឹមត្រូវពីបុគ្គលិកដែលទទួលបានការអនុញ្ញាតពី HLBCAM ។

៥.៤ វិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់ គឺជាឯកសារដែលមិនអាចផ្ទេរបាន ។ អតិថិជនមិនអាចប្រើប្រាស់វិញ្ញាបនប័ត្រនោះជាប្រាតិភោគធានាកាតព្វកិច្ច ទោះក្នុងទម្រង់បែបណាក៏ដោយ។ ម្ចាស់គណនីត្រូវរក្សាទុកវិញ្ញាបនប័ត្រនោះនៅកន្លែងដែលមានសុវត្ថិភាព ក្នុងករណីដែលបាត់វិញ្ញាបនប័ត្រ ម្ចាស់គណនីត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅ HLBCAM។ HLBCAM មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬ ការខូចខាតដែលម្ចាស់គណនីទទួលរង បណ្តាលមកពី ភាពធ្វេសប្រហែស ក្នុងករណីដែលមានការក្លែងបន្លំប្រើប្រាស់វិញ្ញាបនប័ត្រ។ HLBCAM អាចផ្តល់ជូននូវវិញ្ញាបនប័ត្រទុតិយតាក្នុងលក្ខខណ្ឌដែលម្ចាស់គណនីនោះបានចុះហត្ថលេខាលើលិខិតធានាជួសជុលសំណង ។

៥.៥ អតិថិជនអាចស្នើសុំរបាយការណ៍ស្តីពីគណនីប្រាក់បញ្ញើមានកាលកំណត់រៀងរាល់ ប្រចាំខែ និង/ឬ ប្រចាំត្រីមាស ឬ ក្នុងរយៈពេលផ្សេងតាមការកំណត់ដោយ HLBCAM ។ អតិថិជនត្រូវត្រួតពិនិត្យមើលរាល់ទិន្នន័យនៅក្នុងរបាយការណ៍របស់ខ្លួនឱ្យបានច្បាស់លាស់ ឬ ក្នុងករណីអតិថិជនប្រើប្រាស់សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM និងត្រូវធ្វើការជូនដំណឹងមក HLBCAM ជាបន្ទាន់ ប្រសិនបើរកឃើញថាមានកំហុសកើតឡើងនៅក្នុងនោះ។ ប្រសិនបើក្នុងកំឡុងពេល ១៤ (ដប់បួន) ថ្ងៃ (ឬ រយៈពេលផ្សេងទៀតដែលកំណត់ដោយ HLBCAM នៅក្នុងរបាយការណ៍/ការជូនដំណឹង/របាយការណ៍គណនីអេឡិចត្រូនិច (on-line) បន្ទាប់ពីទទួលបាន របាយការណ៍នោះ ឬ ពីកាលបរិច្ឆេទនៃរបាយការណ៍គណនីអេឡិចត្រូនិច (on-line) អតិថិជនមិនបានធ្វើការជំទាស់លើទិន្នន័យព័ត៌មានណាមួយដែលមាននៅក្នុងរបាយការណ៍នោះទេ អតិថិជនត្រូវបានសន្មត់ថាបានទទួលយកទិន្នន័យព័ត៌មានដែលត្រូវបានបញ្ចូនត្រឹមកាលបរិច្ឆេទនៃការបញ្ចូលចុងក្រោយនៅក្នុងរបាយការណ៍គណនីចរន្ត/ក្នុងករណីអតិថិជនប្រើប្រាស់ សេវាកម្មអេឡិចត្រូនិច (on-line) របស់ HLBCAM របាយការណ៍គណនីអេឡិចត្រូនិច (on-line) ត្រឹមត្រូវ និងធានាឱ្យ HLBCAM រួចផុតពីការទទួលខុសត្រូវទាំងអស់ ។

៥.៦ ការប្រាក់ដែលមានអត្រាការប្រាក់ដូច HLBCAM បានព្រមព្រៀងជាមួយម្ចាស់គណនីនឹងត្រូវ ទូទាត់ជូនម្ចាស់គណនីរៀងរាល់ចុងកាលបរិច្ឆេទដល់កាលកំណត់ (ឥណប្រតិទាន) ស្របទៅតាមគោលការណ៍របស់ HLBCAM ។ ម្ចាស់គណនីអាចជ្រើសរើសក្នុងការបញ្ចូលការប្រាក់ ដែលទទួលបានទៅក្នុងគណនីមានកាលកំណត់ ដោយស្វ័យប្រវត្តិ ឬ ទូទាត់ដោយឡែកផ្សេងពីគ្នា។

៥.៧ នៅកាលបរិច្ឆេទដល់កាលកំណត់ (ឥណប្រតិទាន) នៃគណនីប្រាក់បញ្ញើមានកាលកំណត់ ប្រសិនបើ HLBCAM មិនទទួលបាននូវសេចក្តីណែនាំណាមួយ ឬ សេចក្តីណែនាំនោះមិនពេញលេញ ឬ HLBCAM ពុំអាចអនុវត្តបានទៅតាមសេចក្តីណែនាំពីអតិថិជនបាន នោះគណនីប្រាក់បញ្ញើមានកាលកំណត់ត្រូវបន្តសុពលភាពទៅកាលបរិច្ឆេទកំណត់ថ្មីដោយស្វ័យប្រវត្តិដោយមានលក្ខខណ្ឌដូចគ្នាទៅនឹងលក្ខខណ្ឌដែល

ម្ចាស់គណនីបានជ្រើសរើសពីដំបូង HLBCAM រក្សាសិទ្ធិក្នុងការដាក់បញ្ចូលការប្រាក់ដែលអតិថិជនទទួលបានពីកាលកំណត់ចាស់ទៅក្នុងប្រាក់ដើមរបស់គណនីប្រាក់បញ្ញើមានកាលកំណត់ ប្រសិនបើម្ចាស់គណនីមិនបានធ្វើការជ្រើសរើស។ អត្រាការប្រាក់ដែលអនុវត្តទៅលើកាលកំណត់ថ្មី ឬ កាលបរិច្ឆេទ នៃការបន្តសុពលភាព នឹងត្រូវយកមកអនុវត្ត។

៥.៨ រាល់ការដកប្រាក់ជាផ្នែកណាមួយនៅមុនពេលកាលបរិច្ឆេទកំណត់ ត្រូវបានចាត់ទុកថា ជាការដកប្រាក់មុនកាលកំណត់ និងមិនមានការទូទាត់ការប្រាក់ណាមួយសម្រាប់ការដកប្រាក់មុនកាលកំណត់នោះឡើយ លើកលែងតែ HLBCAM យល់ព្រមផ្សេងពីនេះ ។

## ៦. គណនីរួមគ្នា

៦.១ ក្នុងករណីដែលគណនីមួយមានម្ចាស់គណនីពីរ ឬ ច្រើននាក់ បញ្ញត្តិ និងលក្ខខណ្ឌទាំងនេះត្រូវអនុវត្តចំពោះរាល់ម្ចាស់គណនីទាំងអស់ ដោយសាមគ្គីគ្នា និងដោយឡែកពីគ្នា ។ ម្ចាស់គណនីរួមនីមួយៗ ត្រូវទទួលខុសត្រូវរៀងៗខ្លួន លើចំនួនពេញលេញចំពោះ HLBCAM សម្រាប់ប្រតិបត្តិការណាមួយ ដែលត្រូវបានធ្វើឡើងតាមរយៈគណនីរួមនោះ។ រាល់ការស្នើសុំបន្ថែម ឬ ផ្លាស់ប្តូរម្ចាស់គណនីណាម្នាក់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវចុះហត្ថលេខាដោយម្ចាស់គណនីទាំងអស់។ លិខិតស្នើសុំត្រូវមានបញ្ជាក់ពីហេតុផល និងបញ្ជាក់ពីសមតុល្យដែលមាននៅក្នុងថ្ងៃស្នើសុំ។

៦.២ សេចក្តីណែនាំទៅលើទម្រង់ប្រតិបត្តិការគណនីរួម អាចត្រូវបានជ្រើសរើសក្នុងចំណោមទម្រង់ដូចខាងក្រោម៖

ក. ម្ចាស់គណនីណាម្នាក់ / ឬ

ខ. ម្ចាស់គណនីទាំងអស់ / ឬ

គ. ម្ចាស់គណនីចំនួនពីរ ឬ ច្រើននាក់ក្នុងចំណោមម្ចាស់គណនីទាំងអស់។

ប្រភេទប្រតិបត្តិការគណនីដែលបានជ្រើសរើស ត្រូវកត់ត្រានៅក្នុងទម្រង់បែបបទដែល HLBCAM បានកំណត់។

៦.៣ ទម្រង់គណនីរួមបន្ទាប់ ពីត្រូវបានបើក អាចត្រូវបានផ្លាស់ប្តូរលុះត្រាតែមាន ការយល់ព្រមឯកភាពពីម្ចាស់គណនីរួមទាំងអស់។ HLBCAM មិនមានកាតព្វកិច្ចក្នុងការធ្វើប្រតិបត្តិការតាម សេចក្តីណែនាំពីម្ចាស់គណនីម្នាក់ ឬ ច្រើននាក់ចំពោះការផ្លាស់ប្តូរទម្រង់ប្រតិបត្តិការគណនីគណនីនោះឡើយ។ ចំពោះការបិទគណនីរួមក៏ត្រូវមានការយល់ព្រមពីម្ចាស់គណនីទាំងអស់ផងដែរ។

General Terms & Conditions of Accounts

## PART I : GENERAL PROVISIONS

### 1. Definitions

In these Terms & Conditions, the following terms and expressions shall have the meaning designated to them unless the context requires otherwise:

"Account(s)" means the Customer's(s') account or accounts opened and maintained with HLBCAM and shall include any other new accounts which may be opened by the Customer(s) with HLBCAM from time to time.

"Business Account Bearing Interest" means the Account(s) contemplated under Part II Section 2 of these Terms & Conditions.

"Business Current Account" means the Account(s) contemplated under Part II Section 4 of these Terms & Conditions.

"Certificate of Fixed Deposit Receipt" means the record given to the Customer(s) by HLBCAM evidencing a record of the funds the Customer(s) placed into a Fixed Deposit Account held at HLBCAM.

"Customer(s)" means a legal or natural person that buys goods or services from HLBCAM and shall include individuals, partnerships, sole-proprietorships, companies, societies, associations, organizations and statutory bodies and where applicable personal representatives and successors-in-title unless specified otherwise in these Terms & Conditions or by HLBCAM from time to time.

"Fixed Deposit Account" means the Account(s) contemplated under Part II, Section 5 of these Terms & Conditions.

"HLBCAM" means HONG LEONG BANK (CAMBODIA) PLC and includes its branches and its successors-in-title and assigns.

"Joint Account" means the Account(s) contemplated under Part II, Section 2 of these Terms & Conditions.

"NBC" means the National Bank of Cambodia.

"Online Account Statement" means the record, given to the Customer(s), summarizing all transactions in an account during the time from the previous record to the current record that is made available to the Customer(s) online through http://www.hlb.com.my/kh.

“Statement Date” means the date on which the Account statement is made available to the Customer(s).

